## រឿងទី៤៖ ព្រះយេស៊ូត្រាស់ហៅពួកសាវក

**ខគម្ពីរ៖ ម៉ាថាយ៤៖១៩**

ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «សូមអញ្ជើញមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកឲ្យនេសាទមនុស្សវិញ»។

ថ្ងៃមួយ ព្រះយេស៊ូបានយាងទៅសមុទ្រកាលីឡេ ជាកន្លែងដែលពេត្រុសជាអ្នកនេសាទ និងអនទ្រេជាប្អូនធ្លាប់ចាប់ត្រីនៅទីនោះ។

ពេត្រុសនិងអនទ្រេខកចិត្ត ព្រោះពេញមួយយប់គេមិនបានត្រីសូម្បីតែមួយ ពួកគេក៏បានចតទូកនៅមាត់ច្រាំង ហើយលាងអួន។

ពេលនោះ ព្រះយេស៊ូបានយាងមកកន្លែងនោះ។

ហើយមានមនុស្សជាច្រើនមកតាមព្រះយេស៊ូ។

ក្រោយពីព្រះយេស៊ូបានឡើងជិះទូករបស់ពេត្រុស ទ្រង់បានបង្រៀនហ្វូងមនុស្សអំពីនគរព្រះ។

ក្រោយពីព្រះយេស៊ូបានបង្រៀនចប់ ទ្រង់មានព្រះបន្ទូលទៅកាន់ពេត្រុសថា៖

"ចូរបង្ហួសទូកទៅទឹកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ"

ពេត្រុស និងអនទ្រេគឺជាអ្នកនេសាទត្រីជំនាញ។

ពួកគេខំប្រឹងប្រែងរកត្រីពេញមួយយប់ មិនបានត្រីសូម្បីតែមួយ ប៉ុន្តែព្រះយេស៊ូបង្គាប់ឱ្យពួកគេទម្លាក់អួនម្តងទៀត។

ទោះជាអ៊ីចឹងក៏ដោយ ពួកគេបានសាកទម្លាក់អួនចុះតាមបង្គាប់ព្រះយេស៊ូ ។

ពេត្រុសនិងអនទ្រេភ្ញាក់ផ្អើលជាខ្លាំង។

ពីព្រោះក្នុងអួនមានពេញដោយត្រី។

គឺច្រើនលើសលុបស្ទើតែធ្លាយអួនទៅហើយ! យ៉ាកុប និងយ៉ូហានដែលនៅក្បែរនោះ បានឃើញការអស្ចារ្យនេះ ក៏បានក្រាបលុតជង្គង់ចំពោះព្រះយេស៊ូ។

ព្រះយេស៊ូបានមានព្រះបន្ទូលទៅពួកគេថា៖

"កុំខ្លាចអី! ពីពេលនេះទៅមុខ អ្នកនឹងនេសាទមនុស្សវិញ!"

ពួកគេបោះបង់របស់របរទាំងអស់ចោល រួចនាំគ្នាដើរតាមព្រះយេស៊ូទៅ។

ដូច្នេះហើយ តាំងពីពេលនោះមក ពេត្រុស អនទ្រេ យ៉ាកុប និងយ៉ូហានក៏បានក្លាយទៅជាសាវកព្រះយេស៊ូ។





ថ្ងៃមួយព្រះយេស៊ូបានជួបមនុស្សម្នាក់ឈ្មោះលោកម៉ាថាយ។ លោកម៉ាថាយគឺជាអ្នកទារពន្ធ។

កាលនោះ អ្នកទារពន្ធត្រូវបានគេស្អប់ខ្ពើម ដោយព្រោះទារប្រាក់ពីគេយ៉ាងច្រើន។

គេចាត់ទុកអ្នកទារពន្ធជាអ្នកមានបាប តែព្រះយេស៊ូបានយាងទៅរកលោកម៉ាថាយដោយផ្ទាល់ ហើយមានបន្ទូលទៅគាត់ថា៖

«សូមអញ្ជើញមកតាមខ្ញុំ!»

លោកម៉ាថាយឮហើយ បានក្រោកឡើងភ្លាម ចោលអ្វីទាំងអស់ ហើយដើរតាមទ្រង់ទៅ។

ពួកផារិស៊ីឃើញព្រះយេស៊ូបរិភោគអាហាររួមជាមួយអ្នកទារពន្ធជាច្រើននៅផ្ទះលោកម៉ាថាយ ក៏បានរិះគន់ព្រះយេស៊ូ។

ព្រះយេស៊ូក៏មានព្រះបន្ទូលថា៖

«មនុស្សសុខភាពល្អមិនត្រូវការគ្រូពេទ្យទេ មានតែអ្នកជម្ងឺប៉ុណ្ណោះដែលត្រូវការ។ ខ្ញុំមិនមែនមករកមនុស្ស សុចរិត ទេ គឺមករកមនុស្សមានបាប។ ដូច្នេះហើយបានជាខ្ញុំនៅជាមួយពួកគេ។»

ដូច្នេះឯងដែលព្រះយេស៊ូបានត្រាស់ហៅសាវកទាំង១២នាក់។

ពួកសាវកបានរួមដំណើរជាមួយព្រះយេស៊ូបីឆ្នាំ ហើយពួកគេបានរៀនយ៉ាងច្រើនពីទ្រង់។

ហើយបន្ទាប់ពីព្រះយេស៊ូយាងទៅស្ថានសួគ៌វិញ ពួកសិស្សបានធ្វើកិច្ចការជាច្រើនដូចជាទ្រង់ធ្លាប់ធ្វើ។ ពួកគេ បានបង្រៀន ផ្សាយដំណឹងល្អពីព្រះរាជ្យព្រះជាម្ចាស់ និងព្យាបាលជម្ងឺ។



**សកម្មភាពទី១** សូមភ្ជាប់ចម្លើយត្រឹមត្រូវ ទៅនឹងសំណួរនីមួយៗ។

| | |
|---|---|
| តើព្រះយេស៊ូបានគង់នៅជាមួយពួកសាវ័ក ព្រមទាំងបង្រៀនពួកគេ អស់រយៈពេលប៉ុន្មានឆ្នាំ? | ពួកសាវ័កបានផ្សព្វផ្សាយអំពីនគរព្រះ ហើយបានព្យាបាលអ្នកជំងឺ។ |
| ក្រោយពីព្រះយេស៊ូបានយាងឡើងទៅស្ថានសួគ៌ តើសាវ័ករបស់ទ្រង់បានធ្វើអ្វីដូចព្រះអង្គ? | ៣ឆ្នាំ |
| តើអ្នកដែលបានបង់សំណាញ់នៅតាមឆ្នេរសមុទ្រកាលីឡេ មានឈ្មោះអ្វីខ្លះ? | ពេត្រុស និងអនទ្រេ |

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (ម៉ាថាយ៤៖១៩)

ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «សូមអញ្ជើញមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកអោយនេសាទមនុស្សវិញ»។

**សកម្មភាពទី២** សរសេរឈ្មោះសិស្សទាំង១២នាក់របស់ព្រះយេស៊ូតាមលំដាប់លំដោយ ហើយបង្កើតកង់វិល (Roulette)។







**១. ពេត្រុស, ២. អនទ្រេ, ៣. យ៉ាកុប, ៤. ម៉ាថាយ, ៥. យ៉ូហាន, ៦. ថាដេ, ៧. ថូម៉ាស**
**៨. បាថូឡូមេ, ៩. ស៊ីម៉ូន, ១០. យ៉ាកុប (កូនរបស់អាល់ផាយ), ១១. យូដាស, ១២. ភីលីព**